លេខ ៥៤ ចេញផ្សាយថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែធ្នូ ឆ្នាំ២០២៥

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- កិច្ចប្រជុំស្តីពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងដំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ........ទំព័រទី១
- កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)...ទំព័រទី២
- កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ ន.ប.ធ. និងប្រតិភូវិភាគទានច្បាប់........ទំព័រទី២
- សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងប្រកាសស្តីពី" ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច"........ទំព័រទី២
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ផែនការអភិវឌ្ឍកម្មវិធីសិក្សា គណនេយ្យករជំនាញកម្ពុជា ឆ្នាំ២០២៥-២០៣០ និងសេចក្តីសម្រេចស្តីពីគោលការណ៍ទទួលស្គាល់ គ្រឹះស្ថានសិក្សាសម្រាប់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា"........ទំព័រទី៣
- វេទិការដ្ឋាភិបាលឌីជីថល ឆ្នាំ២០២៥ និងព្រឹត្តិការណ៍ជាតិ-អន្តរជាតិពាក់ព័ន្ធ........ទំព័រទី៣
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)........ទំព័រទី៤
- ពិធីប្រគល់-ទទួលអគារសិក្សា ១ខ្នង មាន២បន្ទប់ និងគ្រឿងសង្ហារឹមគ្រប់បន្ទប់ ព្រមទាំងដងទង់ជាតិ នៅសាលាបឋមសិក្សា រំលេច........ទំព័រទី៤
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)........ទំព័រទី៥
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)........ទំព័រទី៥
- សកម្មភាពថ្នាក់ដឹកនាំ និងមន្ត្រី ន.ប.ធ. ចូលរួមបរិច្ចាគឈាមដើម្បីជាកម្លាំងចិត្តជួយគាំទ្រដល់វីរកងទ័ពជួរមុខ........ទំព័រទី៥
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កម្រងបទប្បញ្ញត្តិ និងសទ្ទានុក្រមបច្ចេកវិទ្យាហិរញ្ញវត្ថុ"........ទំព័រទី៦
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម រវាងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.)........ទំព័រទី៦
- កម្មវិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ "ប្រព័ន្ធទទួលបណ្តឹងធានារ៉ាប់រងតាមកម្មវិធីទូរសព្ទដៃ"........ទំព័រទី៦
- កិច្ចប្រជុំពិភាក្សាការងាររវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា........ទំព័រទី៧
- កិច្ចប្រជុំពិភាក្សាការងាររវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយជាមួយគណៈប្រតិភូ Chartered Insurance Institute (CII) មកពីហុងកុង........ទំព័រទី៧
- វគ្គបណ្តុះបណ្តាលស្តីពី "ការកត់ត្រាចំណូល-ចំណាយ គម្រោងប្រកួតប្រជែងខ្សែ-ច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម"........ទំព័រទី៧
- កម្មវិធីសិក្ខាសាលាស្តីពី "ច្បាប់ក្ស័យធន"........ទំព័រទី៨
- សិក្ខាសាលាស្តីពី "ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា និងព្រឹត្តិការណ៍អមកិច្ចប្រជុំហ្វ្រង់កូហ្វូនី (Franco-phonie)"........ទំព័រទី៨
- ពិធីសម្ពោធផ្លូវការ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៥-២០៣០"........ទំព័រទី៩
- កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយវិទ្យាស្ថានគោលនយោបាយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា........ទំព័រទី៩
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង........ទំព័រទី៩
- វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា........ទំព័រទី៩
- កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយប្រតិភូវិភាគទានច្បាប់........ទំព័រទី១០
- កិច្ចប្រជុំក្រុមការងារអន្តរក្រសួងពីផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រស្តីពី "ការអភិវឌ្ឍសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨"........ទំព័រទី១០
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងវិទ្យាស្ថានខេមអេដ........ទំព័រទី១០
- កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី និងក្រុមហ៊ុន សិរីនឌីប ម៉ាយក្រូអ៊ិនសួរេន ម.ក........ទំព័រទី១១
- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៧........ទំព័រទី១១
- សកម្មភាពសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ច ជូនដល់វីរកងទ័ពជួរមុខកំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាពចំនួន ៣ ទីតាំងគោលដៅ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់........ទំព័រទី១១
- សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអចលនវត្ថុនិងបញ្ចាំ ឆ្នាំ២០២៥-២០៣០"........ទំព័រទី១២
- កិច្ចប្រជុំជាមួយស្ថាប័នហិរញ្ញវត្ថុដៃគូ អំពីស្ថានភាពនៃការអនុវត្តការងារក្នុងក្របខ័ណ្ឌនៃគម្រោង ACSEP........ទំព័រទី១២
- សកម្មភាពសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ចចែកជូនដល់បងប្អូនប្រជាពលរដ្ឋខ្មែរភៀសសឹកពីតំបន់មានជម្លោះព្រំដែនកម្ពុជា-ថៃ ចំនួន ៦២០ គ្រួសារ ដែលកំពុងស្នាក់នៅបណ្តោះអាសន្ននៅទីតាំងសុវត្ថិភាពស្ថិតនៅភូមិសាស្ត្រភៀសសឹក ខេត្តសៀមរាប........ទំព័រទី១៣
- សិក្ខាសាលាកសាងសមត្ថភាពមន្ត្រីផ្ទៃក្នុងនៃ ន.ប.ធ. ........ទំព័រទី១៣


## កិច្ចប្រជុំស្តីពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងដំរឿនមន្ត្រីជាក់ស្តែង នៅតាមរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃចន្ទ ១១កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥, ដោយទទួលបានការអនុញ្ញាត ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការធ្វើបច្ចុប្បន្នភាពរចនា-សម្ព័ន្ធនិងដំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**កសហវ**) ក្រោមអធិបតីភាពរបស់ **ឯកឧត្តម មាស សុខសេនសាន រដ្ឋលេខាធិការ កសហវ** និងជាប្រធានក្រុមការងារទទួលបន្ទុកធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងដំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន និងអង្គភាពក្រោមឱវាទ **កសហវ** នៅទីស្តីការ **កសហវ**។



រូបភាព៖ កិច្ចប្រជុំស្តីពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធនិងដំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃចន្ទ ១១កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១ ខែធ្នូ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពី "គោលការណ៍នៃការប្រើប្រាស់ផលចំណេញពីការវិនិយោគមូលនិធិសន្តិសុខសង្គម", សេចក្តីព្រាងប្រកាសស្តីពី "ការកំណត់វិធានប្រុងប្រយ័ត្នលើការបែងចែកកញ្ចប់វិនិយោគនៃមូលនិធិសន្តិសុខសង្គម" របស់និយ័តករសន្តិសុខសង្គម និងសេចក្តីព្រាងប្រកាសស្តីពី "ការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង" របស់និយ័តករគណនេយ្យនិងសវនកម្ម ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ ន.ប.ធ. និងប្រតិភូវិភាគទានច្បាប់

នាព្រឹកថ្ងៃអង្គារ ១២ កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២ ខែធ្នូ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានទទួលការជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយប្រតិភូវិភាគទានច្បាប់ ដឹកនាំដោយ **លោកស្រី ទេព បូផល** ស្ថាបនិកវិភាគទានច្បាប់ និងសហអ្នកនិពន្ធ នៃគម្រោងសរសេរសៀវភៅ "នីតិសន្តតិកម្ម។ ជំនួបនេះ រៀបចំឡើងក្នុងគោលបំណងបញ្ចូលយន្តការ និងទស្សនទាននៃបរធនបាលកិច្ច ទៅក្នុងសៀវភៅនីតិសន្តតិកម្ម ដោយបន្ស៊ីរបបសន្តតិកម្មនៃក្រមរដ្ឋប្បវេណី ជាមួយបរធនបាលកិច្ចគ្រួសារក្នុងវិស័យបរធនបាលកិច្ច។ ជាលទ្ធផលនៃជំនួបនេះ **ន.ប.ធ.** និងវិភាគទានច្បាប់ បានគាំទ្រឲ្យបន្តកិច្ចសហប្រតិបត្តិក្នុងក្របខណ្ឌ៖ ១. បន្តពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ដោយសិក្សាលទ្ធភាពនៃការចុះអនុស្សរណៈយោគយល់គ្នា (MOU) រវាង **ន.ប.ធ.** និងវិភាគទានច្បាប់ ២. រៀបចំសិក្ខាសាសា ឬវគ្គបណ្តុះបណ្តាលអំពីច្បាប់ពាក់ព័ន្ធនឹងសន្តតិកម្ម និងបរធនបាលកិច្ចគ្រួសារឱ្យកាន់តែទូលំទូលាយ ៣. ទទួលនិស្សិតរបស់វិភាគទានច្បាប់ចូលរួមការបណ្តុះបណ្តាលរបស់ **ន.ប.ធ.** ដើម្បីសិក្សាអំពីវិស័យបរធនបាលកិច្ច ក៏ដូចជា ការចែករំលែក និងផ្សព្វផ្សាយក្របខណ្ឌច្បាប់ស្តីពីបរធនបាលកិច្ចក្នុងកម្មវិធីនានារបស់វិភាគទានច្បាប់ ៤.បង្កើតជំនួបប្រជុំពិភាក្សាជាមួយក្រុមវិនិយោគិនធុរជន អ្នកវិជ្ជាជីវៈសេរី និងបរធនបាល ពាក់ព័ន្ធនឹងសន្តតិកម្ម និងបរធនបាលកិច្ចគ្រួសារ។



រូបភាព៖ កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ ន.ប.ធ. និងប្រតិភូវិភាគទានច្បាប់។

## សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងប្រកាសស្តីពី" ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៤កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៤ ខែធ្នូ ឆ្នាំ ២០២៥ នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងប្រកាសស្តីពី" ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** ក្នុងគោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីឱ្យសេចក្តីព្រាងប្រកាសនេះមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ សំដៅដល់ការបង្កើតក្រុមប្រឹក្សា

ដោះស្រាយវិវាទដែលជាតួអង្គសំខាន់នៅក្នុងដំណាក់កាលដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច អនុលោមតាមច្បាប់ស្ដីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈនេះ មានការចូលរួមពីតំណាងសមាគមបរធនបាលកម្ពុជា, ក្រុមហ៊ុនបរធនបាល, ធនាគារដែលជាប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ក្រុមហ៊ុនវាយតម្លៃ, ក្រុមហ៊ុនផ្ដល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច, បរធនធនបាលហិរញ្ញវត្ថុ ព្រមទាំងស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។



**រូបភាព៖** សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈលើសេចក្ដីព្រាងប្រកាសស្ដីពី"ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច"។

## សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ផែនការអភិវឌ្ឍកម្មវិធីសិក្សា គណនេយ្យករជំនាញកម្ពុជា ឆ្នាំ២០២៥-២០៣០ និងសេចក្ដីសម្រេចស្ដីពីគោលការណ៍ទទួលស្គាល់ គ្រឹះស្ថានសិក្សាសម្រាប់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១៤កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៤ ខែធ្នូ គ.ស.២០២៥, ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិ **ន.ប.ធ**,. **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី អញ្ជើញចូលរួមអមជាគណៈអធិបតីក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ផែនការអភិវឌ្ឍកម្មវិធីសិក្សា គណនេយ្យករជំនាញកម្ពុជា ឆ្នាំ២០២៥-២០៣០ និងសេចក្ដីសម្រេចស្ដីពីគោលការណ៍ទទួលស្គាល់ គ្រឹះស្ថានសិក្សាសម្រាប់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ខឹ តាឃី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា** និងមានការអញ្ជើញចូលរួមពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាអនុប្រធានប្រចាំការនៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ព្រមទាំងមានការចូលរួមពីសមាជិក ទីប្រឹក្សា និងលេខាធិការដ្ឋានរបស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា និងឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រុមហ៊ុនគណនេយ្យ និងសវនកម្ម ស្ថាប័នពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទ **កសហវ** រួមទាំងនិស្សិតពីសាកលវិទ្យាល័យមួយចំនួន នៅសណ្ឋាគារភ្នំពេញ។



**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ផែនការអភិវឌ្ឍកម្មវិធីសិក្សា គណនេយ្យករជំនាញកម្ពុជា ឆ្នាំ២០២៥-២០៣០ និងសេចក្ដីសម្រេចស្ដីពីគោលការណ៍ទទួលស្គាល់ គ្រឹះស្ថានសិក្សាសម្រាប់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា"។

## វេទិការដ្ឋាភិបាលឌីជីថល ឆ្នាំ២០២៥ និងព្រឹត្តិការណ៍ជាតិ-អន្តរជាតិពាក់ព័ន្ធ

នាព្រឹកថ្ងៃសុក្រ ១៥កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីបានអញ្ជើញចូលរួម "វេទិការដ្ឋាភិបាលឌីជីថល ឆ្នាំ២០២៥ និងព្រឹត្តិការណ៍ជាតិ-អន្តរជាតិពាក់ព័ន្ធ" ក្រោមប្រធានបទ "ការពន្លឿនអនាគតឌីជីថល៖ អភិបាលកិច្ច កំណើន និងភាពជាដៃគូសកល" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី** តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។



**រូបភាព៖** វេទិការដ្ឋាភិបាលឌីជីថល ឆ្នាំ២០២៥ និងព្រឹត្តិការណ៍ជាតិ-អន្តរជាតិពាក់ព័ន្ធ។



អគារ ១៦៨ F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃសុក្រ ១៥កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៥ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃគម្រោងថវិកាប្រចាំឆ្នាំ២០២៦ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងសេចក្តីព្រាងប្រកាសស្តីពី ការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង របស់និយ័តករគណនេយ្យ និងសវនកម្ម ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## ពិធីប្រគល់-ទទួលអគារសិក្សា ១ខ្នង មាន២បន្ទប់ និងគ្រឿងសង្ហារឹមគ្រប់បន្ទប់ ព្រមទាំងដងទង់ជាតិ នៅសាលាបឋមសិក្សា រំលេច

នារសៀល ថ្ងៃសៅរ៍ ១រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្ត សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីប្រគល់-ទទួលអគារសិក្សា ១ខ្នង មាន២បន្ទប់ និងគ្រឿងសង្ហារឹមគ្រប់បន្ទប់ ព្រមទាំងដងទង់ជាតិ នៅសាលាបឋមសិក្សា រំលេច ដែលស្ថិតនៅភូមិបឹងរំលេច ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្រោមការឧបត្ថម្ភថវិកាសាងសង់របស់បរធនបាលកិច្ចហិរញ្ញវត្ថុ អមតៈ។ ក្នុងពិធីប្រគល់-ទទួលអគារសិក្សានេះ ក៏មានការចូលរួមពី**លោក ជា ផល្លារិន បរធនបាលរូបវន្តបុគ្គលឯករាជ្យនៃបរធនបាលកិច្ចហិរញ្ញវត្ថុ អមតៈ, លោក ជាង ឡេង អភិបាលនៃគណៈអភិបាលស្រុកវាលវែង**, ប្រធាន និងមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡាស្រុកវាលវែង អជ្ញាធរ និងប្រជាការពារភូមិបឹងរំលេច គណៈគ្រប់គ្រង និងលោកគ្រូអ្នកគ្រូសាលាបឋមសិក្សារំលេច ព្រមទាំងសិស្សានុសិស្ស និងមាតាបិតាសិស្ស។ សំណង់អគារសិក្សាដ៏ស្អាត និងមានសោភ័ណភាពនេះ ត្រូវបានរចនាឡើងដោយគិតគូគ្រប់ជ្រុងជ្រោយពីពន្លឺ និងខ្យល់។នាឱកាសនោះ**ឯកឧត្តម សុខ ដារ៉ា** បានមានប្រសាសន៍ពីសារៈសំខាន់នៃការអប់រំ និងបានអំពាវនាវឱ្យមាតា-បិតារបស់សិស្សបញ្ជូនកូនមកចូលរៀននៅសាលាបឋមសិក្សារំលេចឱ្យបានចប់ថ្នាក់ ដើម្បីអនាគតរបស់ក្មេងៗ និងធនធានមនុស្សសម្រាប់កម្ពុជា និងចូលរួមថែរក្សាអគារសិក្សាថ្មីនេះ ឱ្យបានគង់វង្សយូរអង្វែង ដើម្បីរក្សាទុកសម្រាប់ក្មេងៗជំនាន់ក្រោយបានចូលរៀន ក៏ដូចជាកសាងការជឿជាក់ដល់ម្ចាស់ជំនួយ សំដៅជំរុញលើកទឹកចិត្តឱ្យមានការបន្តជួយសាងសង់អគារទាំងនេះ នៅតាមគ្រឹះស្ថានសិក្សា និងសហគមន៍ផ្សេងៗទៀត។



រូបភាព៖ ពិធីប្រគល់-ទទួលអគារសិក្សា ១ខ្នង មាន២បន្ទប់ និងគ្រឿងសង្ហារឹមគ្រប់បន្ទប់ ព្រមទាំងដងទង់ជាតិ នៅសាលាបឋមសិក្សា រំលេច។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃចន្ទ ៣រោចខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពី ក្រមសីលធម៌វិជ្ជាជីវៈរបស់បរធនបាល, សេចក្តីព្រាងប្រកាសស្តីពី ការដាក់ទណ្ឌកម្មខាងវិន័យចំពោះបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច ដែលមិនអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងសេចក្តីព្រាងប្រកាសស្តីពីការបើកសាខារបស់បរធនបាល របស់ **ន.ប.ធ.** ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាអនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃអង្គារ ៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពី ការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច និងសេចក្តីព្រាងប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ច របស់ **ន.ប.ធ.** ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធាន អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## សកម្មភាពថ្នាក់ដឹកនាំ និងមន្ត្រី ន.ប.ធ. ចូលរួមបរិច្ចាគឈាម ដើម្បីជាកម្លាំងចិត្តជួយគាំទ្រដល់វីរកងទ័ពជួរមុខ

ដោយទទួលបានការអនុញ្ញាត និងលើកទឹកចិត្តពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) នាថ្ងៃអង្គារ ៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ មន្ត្រីនៃនិយ័តករបរធនបាលកិច្ច បានចូលរួមបរិច្ចាកឈាម ដើម្បីជាកម្លាំងចិត្តជួយគាំទ្រដល់វីរកងទ័ពជួរមុខ និងជាការតបស្នងចំពោះការលះបង់ដ៏ធំធេងរបស់វីរកងទ័ពជួរមុខក្នុងបុព្វហេតុការពារជាតិ មាតុភូមិ ពីសត្រូវសៀមឈ្លានពាន និងជាការជួយទ្រទ្រង់អាយុជីវិតប្រជាជនតាមព្រំដែន បងប្អូនខ្មែរច្រើនកុះករ រួបរួមជាធ្លុងមួយមកស្ម័គ្រចិត្តបរិច្ចាគឈាមសម្រាប់តម្រូវការបន្ទាន់ណាមួយ នៅសាកលវិទ្យាល័យការពារជាតិ រាជធានីភ្នំពេញ។



រូបភាព៖ សកម្មភាពថ្នាក់ដឹកនាំ និងមន្ត្រី ន.ប.ធ. ចូលរួមបរិច្ចាគឈាមដើម្បីជាកម្លាំងចិត្តជួយគាំទ្រដល់វីរកងទ័ពជួរមុខ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ក្រមងបទប្បញ្ញត្តិ និងសន្ទានុក្រមបច្ចេកវិទ្យាហិរញ្ញវត្ថុ"

នាព្រឹកថ្ងៃអង្គារ ៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥, ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ក្រមងបទប្បញ្ញត្តិ និងសន្ទានុក្រមបច្ចេកវិទ្យាហិរញ្ញវត្ថុ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម មី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ព្រមទាំងមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន នៅសណ្ឋាគារសាន់ & មូន រីវើសាយ។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កម្រងបទប្បញ្ញត្តិ និងសទ្ទានុក្រមបច្ចេកវិទ្យាហិរញ្ញវត្ថុ"។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម រវាងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.)

នារសៀលថ្ងៃពុធ ៥ រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោកស្រី ឈាន សុខរី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច** និងសហការី បានចូលរួមពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម រវាងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (**ស.ហ.ក.**) ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកិច្ចការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់និយ័តករក្រោមឱវាទរបស់ **អ.ស.ហ.** រួមមាន៖ និយ័តករធានារ៉ាប់រងកម្ពុជា,និយ័តករមូលបត្រកម្ពុជា, និយ័តករសន្តិសុខសង្គម,និយ័តករបរធនបាលកិច្ច និងនិយ័តករគណនេយ្យនិងសវនកម្ម។ អនុស្សរណៈនៃការយោគយល់គ្នានេះត្រូវបានរៀបចំឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ អ.ស.ហ.** និង **ឯកឧត្តម ហេង ប៊ុមករា** ប្រធាន **ស.ហ.ក.** ព្រមទាំងមានការចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំនិងមន្ត្រីនៃអង្គភាពក្រោមឱវាទ **អ.ស.ហ.** និង **ស.ហ.ក** នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទាន-ភេរវកម្ម រវាងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (**ស.ហ.ក.**)។

## កម្មវិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ "ប្រព័ន្ធទទួលបណ្តឹងធានារ៉ាប់រងតាមកម្មវិធីទូរសព្ទដៃ"

នៅព្រឹកថ្ងៃព្រហស្បតិ៍ ៦រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១១ ខែធ្នូ គ.ស.២០២៥, ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ឆែម លាបហេង អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច**នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយមន្ត្រីនៃការិយាល័យដោះស្រាយពាក្យបណ្តឹង បានចូលរួមកម្មវិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ "ប្រព័ន្ធទទួលបណ្តឹងធានារ៉ាប់រងតាមកម្មវិធីទូរសព្ទដៃ" រៀបចំដោយនិយ័តករធានារ៉ាប់រងកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ច័ន្ទសិរី** អគ្គនាយកនៃ **ន.ធ.ក.** ដោយមានការអញ្ជើញចូលរួមពីលោក-លោកស្រី ជាអតិថិជនធានារ៉ាប់រង តំណាងក្រុមហ៊ុនធានា-រ៉ាប់រង និយ័តករ និងអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដែលបានធ្វើឡើងនៅសណ្ឋាគារ ឡឺ រ៉ូយ៉ាល់ ភ្នំពេញ ។



រូបភាព៖ កម្មវិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ "ប្រព័ន្ធទទួលបណ្តឹងធានា-រ៉ាប់រងតាមកម្មវិធីទូរសព្ទដៃ"។

## កិច្ចប្រជុំពិភាក្សាការងាររវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃសុក្រ ៧ រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម នច ពិសិដ្ឋ** អគ្គនាយករង និងសហការី បានជួបប្រជុំពិភាក្សាការងារជាមួយ **ឯកឧត្តម សាំង ចណ្ណា៖ ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា** អមដោយសហការី។

កិច្ចប្រជុំពិភាក្សានេះ ផ្តោតជាសំខាន់លើការពង្រឹងកិច្ចសហប្រតិបត្តិការរវាង **ន.ប.ធ.** និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខណ្ឌសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ ដោយពិនិត្យលទ្ធភាពចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) សារជាថ្មី, ការបណ្តុះបណ្តាល ការកសាងសមត្ថភាព និងផ្លាស់ប្តូរចំណេះដឹង, និងការពង្រឹងវិជ្ជាជីវៈក្នុងក្របខណ្ឌវិស័យទាំងពីរ។



**រូបភាព៖** កិច្ចប្រជុំពិភាក្សាការងាររវាងថ្នាក់ដឹកនាំ **ន.ប.ធ.** ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

## កិច្ចប្រជុំពិភាក្សាការងាររវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយជាមួយគណៈប្រតិភូ Chartered Insurance Institute (CII) មកពីហុងកុង

នាព្រឹកថ្ងៃចន្ទ ១០ រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូ Chartered Insurance Institute (CII) មកពីហុងកុង តំណាងដោយ **លោក-Yip Kwok Fai (Thomas) អនុប្រធានក្រុមប្រឹក្សាភិបាល** និង **លោក Kenny Siu នាយកគ្រប់គ្រងតំបន់** នៃ CII អំពីកម្មវិធីបណ្តុះបណ្តាលស្តីពី "Family Trust Training Program" ក្នុងគោលបំណងដើម្បីពិនិត្យលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការ និងយន្តការសមស្របសម្រាប់ការផ្តល់កិច្ចសហការទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព សំដៅជំរុញការអភិវឌ្ឍបរធនបាលកិច្ចគ្រួសារនៅកម្ពុជា ក៏ដូចជានឹងផ្តល់ឱកាសអាទិភាពដល់មន្ត្រីនៃ **ន.ប.ធ.** ព្រមទាំងប្រតិបត្តិករពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចបង្កើនសមត្ថភាព និងចំណេះដឹងបន្ថែម។



**រូបភាព៖** ជាមួយគណៈប្រតិភូ Chartered Insurance Institute (CII) មកពីហុងកុង។

## វគ្គបណ្តុះបណ្តាលស្តីពី "ការកត់ត្រាចំណូល-ចំណាយ គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម"

នាព្រឹកថ្ងៃចន្ទ ១០ កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU1), **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1** បានដឹកនាំក្រុមការងាររៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការកត់ត្រាចំណូល-ចំណាយ គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម" នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីសហគមន៍កសិកម្ម កសិករផលិត ក៏ដូចជាម្ចាស់សហគ្រាសកសិធុរកិច្ចទទួលបានព័ត៌មានបន្ថែមអំពីសារៈប្រយោជន៍ និងទម្រង់នានានៃការកត់ត្រាចំណូល-ចំណាយក្នុងអាជីវកម្មជាប្រចាំថ្ងៃ។ វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីសមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1 និងតំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃខេត្តគោលដៅរបស់គម្រោង។



រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី "ការកត់ត្រាចំណូល-ចំណាយ គម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម"។

## កម្មវិធីសិក្ខាសាលាស្តីពី "ច្បាប់ក្ស័យធន"

នាព្រឹកថ្ងៃអង្គារ ១១រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៦ ខែធ្នូ គ.ស.២០២៥ និយ័តករបរធនបាលកិច្ច, និយ័តករមូលបត្រកម្ពុជា, និយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថានខេមអេដ និងដោយមានការគាំទ្រពីក្រុមហ៊ុន ស្រ្តងហូល ត្រាសធី ឯ.ក បានសហការគ្នារៀបចំកម្មវិធីសិក្ខាសាលាស្តីពី "ច្បាប់ក្ស័យធន" នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ូ សុជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា**, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តម ម៉ៅ ច័ន្ទតិរ្យ** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅដើម្បីពង្រឹងសមត្ថភាពមន្ត្រីនៃនិយ័តករមូលបត្រកម្ពុជា, និយ័តករបរធន-បាលកិច្ច និងនិយ័តករធានារ៉ាប់រងកម្ពុជា លើនីតិវិធីនៃការក្ស័យធន, កំណត់នីតិវិធី និងលក្ខខណ្ឌសម្រាប់ដោះស្រាយស្ថានភាពដែលបុគ្គលឬអាជីវកម្ម មិនអាចសង់បំណុលបាន តាមកាលកំណត់ និងការទទួល-ខុសត្រូវ និងដើម្បីអាចបំពេញបន្ថែមលើបទប្បញ្ញត្តិស្តីពីក្ស័យធននៃវិស័យទាំង ៣។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីជំនាញ នៃនិយ័តករទាំង ៣, ក្រុមហ៊ុនពាក់ព័ន្ធក្នុងវិស័យទាំង ៣ និងវាគ្មិនកិត្តិយស លោកបណ្ឌិត ព្រំ វីរៈ ប្រធានក្រុម-ប្រឹក្សាភិបាល នៃវិទ្យាស្ថាន ខេមអេដ។



រូបភាព៖ កម្មវិធីសិក្ខាសាលាស្តីពី "ច្បាប់ក្ស័យធន"។

## សិក្ខាសាលាស្តីពី "ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា និងព្រឹត្តិការណ៍អមកិច្ចប្រជុំហ្វ្រង់កូហ្វូនី (Franco-phonie)"

នៅថ្ងៃអង្គារ ១១រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៦ ខែធ្នូ គ.ស.២០២៥, ដោយទទួលបានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានចូលរួមកិច្ចប្រជុំពិភាក្សាត្រៀមរៀបចំសិក្ខាសាលាស្តីពី "ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា និងព្រឹត្តិការណ៍អមកិច្ចប្រជុំហ្វ្រង់កូហ្វូនី (Franco-phonie)" នៅសណ្ឋាគារ សុខា ខេត្តព្រះសីហនុ រៀបចំដោយគណៈ-កម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (**គ.ក.ច.**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គ.ក.ច.** ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធរួមមាន តំណាងក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និយ័តករក្រោមឱវាទរបស់ **អ.ស.ហ.** អគ្គនាយដ្ឋានពន្ធដារ មជ្ឈមណ្ឌលមជ្ឈិតកម្មជាតិ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។



រូបភាព៖ សិក្ខាសាលាស្តីពី "ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា និងព្រឹត្តិការណ៍អមកិច្ចប្រជុំហ្វ្រង់កូហ្វូនី (Franco-phonie)"។

## ពិធីសម្ពោធផ្លូវការ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៥-២០៣០"

នាព្រឹកថ្ងៃពុធ ១២រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមពិធីសម្ពោធផ្លូវការ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៥-២០៣០" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** នៅសណ្ឋាគារហៃយ៉ាត់រីជិនស៊ី ភ្នំពេញ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងវិទ្យាស្ថានស្រាវជ្រាវនានា។



**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"។

## សកម្មភាពបរិច្ចាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃ ន.ប.ធ. ជូនវីរ-កងទ័ពជួរមុខ និងគ្រួសារភៀសសឹក

ក្នុងស្មារតីរួបរួម សាមគ្គីជាតិខ្មែរ ខ្មែរជួយខ្មែរ, ក្រុមការងារជួរក្រោយនៃនិយ័តករបរធនបាលកិច្ច ចូលរួមទាំងកម្លាំង សម្ភារៈ និងថវិកា ព្រមទាំងផ្តល់ការគាំទ្រដល់វីរកងទ័ពជួរមុខកម្ពុជា និងគ្រួសារភៀសសឹក ដែលកំពុងមានតម្រូវការជាចាំបាច់ ក្នុងគ្រាដ៏សែនលំបាកនេះដែលកើតចេញពីការឈ្លានពានសារជាថ្មីកាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ រហូតមកដល់ពេលនេះ។



**រូបភាព៖** សកម្មភាពបរិច្ចាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** ជូនវីរកង-ទ័ពជួរមុខ និងគ្រួសារភៀសសឹក។

## កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយវិទ្យាស្ថានគោលនយោបាយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

នាព្រឹកថ្ងៃចន្ទ ៣ កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានទទួលជួបពិភាក្សាការងារជាមួយវិទ្យាស្ថានគោល-នយោបាយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (Science and Techonology Policy Institution- STEPI ) មកពីសាធារណរដ្ឋកូរ៉េ តំណាងដោយ**លោក Lee Jungwon អនុប្រធាននៃ STEPI , លោក Dong-Un Park នាយកដ្ឋានស្រាវជ្រាវសកលនៃ STEPI និងកញ្ញា SO-Jeaweon ជាលេខាធិការ** ក្នុងគោលបំណងសិក្សាអំពីសមិទ្ធិលទ្ធភាពសហប្រតិបត្តិការ ដើម្បីជំរុញការអភិវឌ្ឍធនធានមនុស្ស និងបច្ចេកវិទ្យាក្នុងវិស័យបរធនបាលកិច្ច។



**រូបភាព៖** កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ **ន.ប.ធ.** ជាមួយវិទ្យាស្ថានគោល-នយោបាយវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា

នាព្រឹកថ្ងៃចន្ទ ៣កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **លោក ឃុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈុន សម្បត្តិ**

ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** និងលោក **យុន ដារិទ្ធ ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា** ព្រមទាំងមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។



រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា។

## កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយប្រតិភូវិភាគទានច្បាប់

នារសៀលថ្ងៃចន្ទ ៣កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥, ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច** អមដោយសហការី បានជួបប្រជុំជាមួយប្រតិភូវិភាគទានច្បាប់ ដឹកនាំដោយ **លោកស្រីមេធាវី ទេព បូផល ស្ថាបនិកវិភាគទានច្បាប់** និងលោក/លោកស្រីមេធាវី សហអ្នកនិពន្ធ ក្នុងគោលបំណងដើម្បីពិភាក្សាការងារលើក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ច ដែលពាក់ព័ន្ធនឹងការធ្វើសន្តតិកម្ម ក្នុងន័យទទួលបានជាតុចូលបន្ថែមលើការរៀបចំការសរសេរសៀវភៅ "នីតិសន្តតិកម្ម" នៅទីស្តីការនៃ **ន.ប.ធ.**។



រូបភាព៖ កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយប្រតិភូវិភាគទានច្បាប់។

## កិច្ចប្រជុំក្រុមការងារអន្តរក្រសួងពីផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រស្តីពី "ការអភិវឌ្ឍសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨"

ព្រឹកថ្ងៃអង្គារ ៤កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក ចេស ចាន់ដេត ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យានៃនាយកដ្ឋានកិច្ចការទូទៅ** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីពិនិត្យលើវឌ្ឍនភាពការងារ និងកំណត់ទិសដៅការងារបន្តសម្រាប់ធុរកិច្ចឆ្នាំ២០២៦ ក៏ដូចជាពិនិត្យលើផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រស្តីពី "ការអភិវឌ្ឍសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (**កសហវ**) និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ព្រមទាំងជាប្រធានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច នៅសាលប្រជុំអគារ "យ" នៃទីស្តីការ **កសហវ**។



រូបភាព៖ កិច្ចប្រជុំក្រុមការងារអន្តរក្រសួងពីផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រស្តីពី "ការអភិវឌ្ឍសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨"។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងវិទ្យាស្ថានខេមរដ

នាព្រឹកថ្ងៃអង្គារ ៤កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥, ដោយទទួលបាន

ការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងវិទ្យាស្ថានខេមអេដ (**វ.ខ.អ.**) ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈុន សម្បត្តិ ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ., លោក ខេស៊ី បាណោត នាយកនៃវិទ្យាស្ថានខេមអេដ** និង **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។



រូបភាព៖ កិច្ចប្រជុំក្រុមការងារអន្តរក្រសួងពីផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រស្តីពី "ការអភិវឌ្ឍសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨"។

## កិច្ចពិភាក្សារវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី និងក្រុមហ៊ុន សិរិនឌីប ម៉ាយ-ក្រូអ៊ិនស្វូរេន ម.ក

នារសៀលថ្ងៃចន្ទ ៣កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានអញ្ជើញទទួលជួបពិភាក្សាជាមួយ **លោក សុខ រឿន នាយកប្រតិបត្តិនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** និង**លោក សែន គីរី នាយកប្រតិបត្តិ នៃក្រុមហ៊ុន សិរិនឌីប ម៉ាយក្រូអ៊ិនស្វូរេន ម.ក** និងសហការី ដើម្បីពិភាក្សាអំពីកាលានុវត្តភាពសម្រាប់ការប្រកបអាជីវកម្មក្នុងវិស័យបរធនបាលកិច្ច ការវិនិយោគ និងការឈ្វេងយល់អំពីវឌ្ឍនភាពនៃទីផ្សារបរធនបាលកិច្ចនៅកម្ពុជា។



រូបភាព៖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកក្កដា ឆ្នាំ២០២៥។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៧

នាព្រឹកថ្ងៃពុធ ៥កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ និងឯកឧត្តមអគ្គនាយកដែលជាសមាជិក-សមាជិកានៃ **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំនៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៧។

## សកម្មភាពសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ច ជូនដល់វីរកងទ័ពជួរមុខកំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាពចំនួន ៣ ទីតាំងគោលដៅ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់

នៅថ្ងៃព្រហស្បតិ៍ ៦កើត ខែបុស្ស ឆ្នាំម្សាញ់ ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក

នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសហការីបានចុះសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ច ជូនដល់វីរកងទ័ពជួរមុខ ដែលបានរងរបួសក្នុងកំឡុងពេលប្រយុទ្ធនៅសមរភូមិ ជាមួយចោរសៀមឈ្លានពានដែនអធិបតេយ្យកម្ពុជា និងកំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាព ចំនួន ៣ ទីតាំងគោលដៅ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់។

ដំណើរចុះសួរសុខទុក្ខនាពេលនេះធ្វើឡើងក្នុងស្មារតីសាមគ្គីជាតិ «ខ្មែរជួយខ្មែរ» មហាគ្រួសារខ្មែរជាធ្លុងមួយ ឈរពីក្រោយរាជរដ្ឋាភិបាល និងវីរកងទ័ពប្រឆាំងនឹងការឈ្លានពានដ៏សាហាវឃោរឃៅរបស់ប្រទេសថៃ ដោយបានប្រើប្រាស់អាវុធធុនតូច និងធំគ្រប់ប្រភេទរួមទាំងយន្តហោះចម្បាំង គ្រាប់បែកចង្កោមនិងផ្សែងពុលបាញ់ស្រោចដ៏កំរោល ដោយមិនរើសគោលដៅយ៉ាងសាហាវព្រៃផ្សៃចូលយ៉ាងជ្រៅក្នុងដែនអធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ធ្វើឱ្យប្រជាជនស្លូតត្រង់ បាត់បង់អាយុជីវិត និងរងរបួសជាច្រើន, ហេដ្ឋារចនាសម្ព័ន្ធស៊ីវិល សាលារៀន និងផ្ទះសម្បែងប្រជាជនជាច្រើនខ្ទង់ត្រូវបានបំផ្លាញ, ប្រជាជន និងសិស្សសាលា ក្មេងចាស់ប្រុសស្រីត្រូវបង្ខំចិត្តភៀសខ្លួនរកទីកន្លែងសុវត្ថិភាពបណ្តោះអាសន្នភ្លាមៗ ដែលបង្កនូវ វិបត្តិមនុស្សធម៌យ៉ាងធ្ងន់ធ្ងរ ចាប់តាំងពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ រហូតមកនេះ។



**រូបភាព៖** សកម្មភាពសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ច ជូនដល់វីរកងទ័ពជួរមុខកំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាពចំនួន ៣ ទីតាំងគោលដៅ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តពោធិ៍សាត់។

## សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអចលនវត្ថុនិងបញ្ចាំ ឆ្នាំ២០២៥-២០៣០"

នាព្រឹកថ្ងៃសុក្រ ៧កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៦ ខែធ្នូ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីបានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអចលនវត្ថុនិងបញ្ចាំ ឆ្នាំ២០២៥-២០៣០" ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) នៅសណ្ឋាគារភ្នំពេញ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីតំណាងនិយ័តករ-អង្គភាពក្រោមឱវាទ **អ.ស.ហ.** និងភាគីពាក់ព័ន្ធក្នុងវិស័យអចលនវត្ថុនិងបញ្ចាំ។



**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអចលនវត្ថុនិងបញ្ចាំ ឆ្នាំ២០២៥-២០៣០"។

## កិច្ចប្រជុំជាមួយស្ថាប័នហិរញ្ញវត្ថុដៃគូ អំពីស្ថានភាពនៃការអនុវត្តការងារក្នុងក្របខ័ណ្ឌនៃគម្រោង ACSEP

នាព្រឹកថ្ងៃសុក្រ ៧កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៦ ខែធ្នូ គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU1), **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង** ACSEP-PIU1 អមដោយសហការីបានដឹកនាំក្រុមការងាររៀបចំកិច្ចប្រជុំជាមួយស្ថាប័នហិរញ្ញវត្ថុដៃគូ អំពីស្ថានភាពនៃការអនុវត្តការងារក្នុងក្របខ័ណ្ឌនៃគម្រោង ACSEP នៅទីស្តីការនៃ **ន.ប.ធ.**។ កិច្ចប្រជុំនេះ ត្រូវបានរៀនចំឡើងក្នុងគោលបំណងដើម្បីការពិនិត្យ និងវាយតម្លៃស្ថានភាពនៃការអនុវត្តគម្រោង បញ្ហាប្រឈម និងដំណោះស្រាយ និងមានការចូលរួមពីក្រុមការងារអញ្ជើញមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



**រូបភាព៖** កិច្ចប្រជុំជាមួយស្ថាប័នហិរញ្ញវត្ថុដៃគូ អំពីស្ថានភាពនៃការអនុវត្តការងារក្នុងក្របខ័ណ្ឌនៃគម្រោង ACSEP។

## សកម្មភាពសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ច ចែកជូនដល់បងប្អូនប្រជាពលរដ្ឋខ្មែរភៀសសឹកពីតំបន់មានជម្លោះព្រំដែនកម្ពុជា-ថៃ ចំនួន ៦២០ គ្រួសារ ដែលកំពុងស្នាក់នៅបណ្ដោះអាសន្ននៅទីតាំងសុវត្ថិភាពស្ថិតនៅភូមិសាស្រ្តភៀសសឹក ខេត្តសៀមរាប

នាថ្ងៃចន្ទ ១០កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥, ក្នុងស្មារតីសាមគ្គីជាតិខ្មែរ ខ្មែរជួយខ្មែរ និងដើម្បីចូលរួមចំណែកជួយសម្រាលទុក្ខលំបាករបស់បងប្អូនប្រជាពលរដ្ឋខ្មែរភៀសសឹកដែលកំពុងទទួលរងផលប៉ះពាល់ពីសង្គ្រាមឈ្លានពានរបស់កងទ័ពថៃមកលើអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដីកម្ពុជា, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងលោកជំទាវ អមដោយថ្នាក់ដឹកនាំ និងសហការីនៃ **ន.ប.ធ.** បានចុះសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ចចែកជូនដល់បងប្អូនប្រជាពលរដ្ឋខ្មែរភៀសសឹកពីតំបន់មានជម្លោះព្រំដែនកម្ពុជា-ថៃ ចំនួន ៦២០ គ្រួសារ ដែលកំពុងស្នាក់នៅបណ្ដោះអាសន្ននៅទីតាំងសុវត្ថិភាពស្ថិតនៅភូមិសាស្រ្តភៀសសឹក ខេត្តសៀមរាប។

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីនៃ**ន.ប.ធ.**ព្រមទាំងសប្បុរសជនក្នុងវិស័យបរធនបាលកិច្ច សូមចូលរួមចំណែកដោយដួងចិត្តស្មោះស្ម័គ្រ និងសូមបង្ហាញពីការប្ដេជ្ញាចិត្តខ្ពស់ចំពោះទំនួលខុសត្រូវសង្គម សាមគ្គីភាព ស្មារតីខ្មែរតែមួយ គ្រប់កាលៈទេសៈ និងសហការគ្នាយ៉ាងស្វាហាប់ដ៏មុតមាំ ដោយក្ដីមោទនភាពចំពោះគុណវីរភាពកងទ័ពកម្ពុជានៃការលះបង់យ៉ាងធំធេងមិនអាចកាត់ថ្លៃបាន ដើម្បីការពារជាតិមាតុភូមិកម្ពុជាពីខ្មាំងសត្រូវ។



រូបភាព៖ សកម្មភាពសួរសុខទុក្ខ និងនាំយកអំណោយពីវិស័យបរធនបាលកិច្ចចែកជូនដល់បងប្អូនប្រជាពលរដ្ឋខ្មែរភៀសសឹកពីតំបន់មានជម្លោះព្រំដែនកម្ពុជា-ថៃចំនួន ៦២០ គ្រួសារដែលកំពុងស្នាក់នៅបណ្ដោះអាសន្ននៅទីតាំងសុវត្ថិភាពស្ថិតនៅភូមិសាស្រ្តភៀសសឹក ខេត្តសៀមរាប។

## សិក្ខាសាលាកសាងសមត្ថភាពមន្ត្រីផ្ទៃក្នុងនៃ ន.ប.ធ.

នាថ្ងៃអង្គារ ១១កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំចំនួន៣ (បី) រួមមាន៖ ១).គោលការណ៍ណែនាំស្ដីពី "ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ **ន.ប.ធ.**", ២). គោលការណ៍ណែនាំស្ដីពី "ការជ្រើសរើសមន្ត្រី" និង ៣).សេចក្ដីណែនាំស្ដីពី "ការប្រើប្រាស់ប្រព័ន្ធម៉ាស៊ីនមេ (Server) សម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរបស់ **ន.ប.ធ.**" ដើម្បីបញ្ជ្រាបការយល់ដឹងផ្ទៃក្នុងដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** ក្នុងគោលបំណងជំរុញឱ្យមាននិយាមច្បាស់លាស់ក្នុងការអនុវត្តការងារក្នុងក្របខណ្ឌផ្ទៃក្នុងរបស់ **ន.ប.ធ.** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ ឯកឧត្តម/លោកអគ្គនាយករង លោក/លោកស្រីប្រធាននាយកដ្ឋាន និងមន្ត្រីទាំងអស់នៃ **ន.ប.ធ.** នៅសណ្ឋាគារ ខេមរាអង្គរ និងស្ប៉ា ខេត្តសៀមរាប។



រូបភាព៖ សិក្ខាសាលាកសាងសមត្ថភាពមន្ត្រីផ្ទៃក្នុងនៃ ន.ប.ធ.។